# កំណត់សំគាល់ ផ្នែកច្បាប់
# ស្តីពី
# កាតព្វកិច្ចចុះបញ្ជីពន្ធដារ
# សម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ( NGOs )

## ប្រវត្តិ

ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពី សារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែមករា ឆ្នាំ ១៩៩៧។

ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៥ ប្រកាសឲ្យប្រើច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៥។

ប្រកាសលេខ ៨៦៨/សហវ.ប្រក ស្តីពី ការណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធ របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី **១២ខែមេសា ឆ្នាំ២០១៨។**

ប្រកាសលេខ ០៩៨/សហវ.ប្រក ស្តីពីពន្ធលើប្រាក់ចំណូល ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៩ខែមករា ឆ្នាំ២០២០។

ប្រកាសលេខ ៧០១/សហវ.ប្រក ស្តីពីពន្ធការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៤ខែសីហា ឆ្នាំ២០២០។

សេចក្តីណែនាំលេខ ០០៦ សហវ ស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីពន្ធដារ ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ៣០ខែមករា ឆ្នាំ២០១៩។

សេចក្តីណែនាំលេខ ៣០៣៣ អពដ ស្តីពីការចុះបញ្ជីអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

## ការចុះបញ្ជីពន្ធដារសម្រាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត្តិចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។

សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅ ក្រសួងមហាផ្ទៃ ឬចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវស្ថិតនៅក្រោមនីតិវិធី នៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់និងបទបញ្ញាត្តិជាធរមាន ។[1]

បុគ្គលទាំងឡាយដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រពន្ធអេឡិកត្រូនិច (E-Registration) តាមគេហទំព័រ https://www.registrationservice.gov.kh ដោយត្រូវបំពេញទម្រង់ចុះបញ្ជី ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងតម្រូវអោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

### ១.ការចុះបញ្ជីពន្ធដារសម្រាប់ការិយាល័យតំណាង

អ្នកជាប់ពន្ធត្រូវបំពេញទម្រង់ 101-P3 និងត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖

- លិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួងពាណិជ្ជកម្មឬក្រសួង-ស្ថាប័នពាក់ព័ន្ធ (ប្រសិនបើមាន)។
- លក្ខន្តិកៈរបស់ក្រុមហ៊ុនមេ
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមេ
- លិខិតប្រគល់សិទ្ធិតែងតាំងនាយកការិយាល័យតំណាង នាយកសាខា ឬអ្នកតំណាង
- លិខិតប្រកាសដោយសុទ្ធចិត្តអំពីការពុំមានជាប់ទោសពៃរ៍ក្នុងកិច្ចពាណិជ្ជកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងពុំមែនជាមន្រ្តីរាជការក្រសួង ឬស្ថាប័នរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់នាយក ឬអ្នកតំណាង។ រូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នខុស ពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់ នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

[1] មាត្រា ២០ នៃច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ ២០១៥

- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹករបស់នាយកឬអ្នកតំណាង។
- ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមកាទីតាំងរបស់ទីស្នាក់ការឬទីចាត់ការសហគ្រាស។ ទីតាំងដែលគ្មានអគារ ឬជាដីទំនេរ ឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាត ឱ្យប្រើប្រាស់សម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ។
- លិខិតជូនដំណឹងស្តីពីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ ប្រសិនមានអ្នកទទួលបន្ទុកជំនួស។
- លិខិតបញ្ជាក់ព័ត៌មានគណនីធនាគាររបស់សហគ្រាស ដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគារ ឬរបាយការណ៍ធនាគារ ឬសៀវភៅគណនីធនាគារ) ត្រូវផ្តល់ក្រោយពេលទទួលបានការអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ។
- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត សម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គលគ)។[2]

## ២.ការចុះបញ្ជីពន្ធដារសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

អ្នកជាប់ពន្ធត្រូវបំពេញទម្រង់ 101-P1 និងត្រូវភ្ជាប់ ឯកសារដូចខាងក្រោម៖

- លិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាត ចេញដោយរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។
- លក្ខន្តិកៈឬអនុស្សរណៈជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ(ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន ដែលមានសុពលភាពរបស់ប្រធានស្ថាប័នឬអ្នកតំណាងរូបវន្តបុគ្គលដែលជាកម្មវត្ថុក្នុងការបំពេញព័ត៌មានក្នុងពាក្យស្នើសុំនេះ ដែលមានអាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនត្រូវភ្ជាប់បន្ថែមនូវសៀវភៅគ្រួសារឬសៀវភៅស្នាក់ នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល០៣ខែ ដែលមានទំហំ ៣៥ x ៤៥ មិល្លីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌ស ចំនួន០២ សន្លឹក របស់ប្រធានស្ថាប័ន ឬអ្នកតំណាង។

[2] https://www.tax.gov.kh/km/content-detail/xynp29293467775779

- ប័ណ្ណកម្មសិទ្ធិទីតាំង ឬកិច្ចសន្យាជួលទីតាំង ដែលមានព័ត៌មានចំណុចនិយាមកាទីតាំងរបស់ទីស្នាក់ការឬទីចាត់ការសហគ្រាស ។ទីតាំងដែលគ្មានអគារ ឬជាដីទំនេរ ឬមានសំណង់ទើបតែសាងសង់ដែលមិនអាចប្រើប្រាស់បាន មិនត្រូវបានអនុញ្ញាត ឱ្យប្រើប្រាស់សម្រាប់ការចុះបញ្ជីពន្ធដារបានឡើយ វៀរលែងតែមានការយល់ព្រមពីអគ្គនាយកដ្ឋានពន្ធដារ។
- លិខិតជូនដំណឹងស្តីពីការផ្ទេរសិទ្ធិដល់បុគ្គលទទួលបន្ទុកកិច្ចការពន្ធដារ ប្រសិនបើមានអ្នកទទួលបន្ទុកជំនួស។
- លិខិតបញ្ជាក់ព័ត៌មានគណនីធនាគាររបស់ស្ថាប័ន ដែលចេញដោយធនាគារ (លិខិតបញ្ជាក់គណនីធនាគាររបាយការណ៍ធនាគារឬសៀវភៅគណនីធនាគារ) វៀងលែងតែស្ថាប័នរដ្ឋ។[3]

## ៣.ការសុំធ្វើបច្ចុប្បន្នភាពពត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី

អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរពត៌មានដូចខាងក្រោម ៖

ក.អាសយដ្ឋាន

ខ. ទ្រង់ទ្រាយទីចាត់ការ

គ.នាមករណ៍អាសយដ្ឋាន

ឃ. កម្មវត្ថុអាជីវកម្ម ឬស្ថានភាពអាជីវកម្ម

ង.ការផ្ទេរ ការផ្លាស់ប្តូរភាគហ៊ុន

ច. សមាសភាពអ្នកគ្រប់គ្រងសហគ្រាស ឬសាខា

ឆ.ការបញ្ឈប់អាជីវកម្ម

ជ.អ្នកទទួលបន្ទុកកិច្ចការពន្ធ

ឈ.ពត៌មានគណនីធនាគារ

ញ.ពត៌មានទំនាក់ទំនង លេខទូរស័ព្ទ សារអេឡិកត្រូនិក[4]

## ៤.កម្រៃសេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពពត៌មាន

### ៤.១.កម្រៃសេវាចុះបញ្ជី

[3] https://www.tax.gov.kh/km/content-detail/xynp29293467775779

[4] ប្រកា ៥ នៃប្រកាសលេខ ៧០១ សហវ/ប្រក ឆ្នាំ ២០២០

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ ។
- ២០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ ខែណាមួយដែលបញ្ចប់ក្នុងប្រតិទិនចរន្តក្រោម ៦០ លានរៀល ។
- ៤០០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគម និងអង្គការនានា ។

### ៤.២.តម្លៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន

- ០ រៀល សម្រាប់ស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបា
- លនានា និងគណបក្សនយោបាយ ។
- ១០ ០០០ រៀល សម្រាប់អ្នកជាប់ពន្ធតូច និងអ្នកជាប់ពន្ធដែលមានកម្រិតផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល ឬមានផលរបរក្នុងរយៈពេល ០៣ ខែណាមួយដែលបញ្ចប់ក្នុងប្រតិទិនចរន្តក្រោម ៦០ លានរៀល ។
- ២០០ ០០០រៀល សម្រាប់អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ សមាគមនិងអង្គការនានា។[5]

## ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយខ្សែក

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពដោយខ្សែក និងមិនស្ថិតក្នុងគោលដៅ សុទ្ធសាធរបស់ខ្លួនត្រូវបានចាត់ទុកថា ធ្វើសកម្មភាពអាជីវកម្មដោយខ្សែក ដែលត្រូវចុះបញ្ជីនិងត្រូវជាប់ពន្ធតាមច្បាប់និងបទបញ្ញាត្តិស្តីពីពន្ធដារជាធរមាន ។[6]

### ១.ការចុះបញ្ជីចំពោះសកម្មភាពអាជីវកម្មដោយខ្សែក

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពដោយខ្សែកត្រូវបានចាត់ទុកថាជាសហគ្រាសឯកបុគ្គល និងត្រូវចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ ថ្ងៃក្រោយពីមានសកម្មភាពអាជីវកម្មទៅតាមកម្រឹតផលរបរ និងប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលរួមមាន ការចុះបញ្ជីជាអ្នកជាប់ ពន្ធតូច ពន្ធមធ្យម និង ពន្ធធំ ។ ដោយតម្រូវភ្ជាប់ឯកសារផ្សេងៗ

[5] ប្រការ ០៦ នៃប្រកាសលេខ ៧០១ សហវ/ប្រក ឆ្នាំ ២០២០

[6] សេចក្តីណែនាំលេខ ៣០៣៣ របស់អគ្គនាយកដ្ឋានពន្ធដារ ឆ្នាំ ២០២០

ទៅតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ។[7]

### ២.កិច្ចបញ្ជីគណនេយ្យ

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានសកម្មភាពអាជីវកម្មដោយឡែកត្រូវ ៖

- ញែកដាច់ពីគ្នារវាងដើមទុនវិនិយោគ ទ្រព្យសកម្ម ទ្រព្យអកម្ម បុគ្គលិក កម្មករអ្នកគ្រប់គ្រង និងពត៌មានហិរញ្ញវត្ថុផ្សេងៗ សម្រាប់បម្រើអោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសម្រាប់បម្រើអោយ សកម្មភាពអាជីវកម្មដោយឡែក ។
- អនុវត្តវិធាននិងគោលការណ៍នៃបញ្ជីគណនេយ្យសាមញ្ញស្របតាមប្រកាសលេខ ១៨២០ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៥ ស្តីពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច ។
- អនុវត្តវិធានគណនេយ្យតាមស្តង់ដារគណនេយ្យ អន្តរជាតិនៃកម្ពុជា ស្របតាមបទបញ្ញាត្តិស្តីពីពន្ធលើប្រាក់ចំណូល សម្រាប់អ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ ។

## ភាតព្វកិច្ចប្រកាសបង់ពន្ធ

អង្គការ សមាគម អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធ ជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែង ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

លិខិតប្រកាសពន្ធត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។[8]

### ១.ការកាន់បញ្ជីភាគណនេយ្យ

អ្នកជាប់ពន្ធ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា៖

- ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។
- ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាព សេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

### ២.វិធានវិក្កយបត្រ

អ្នកជាប់ពន្ធមធ្យមត្រូវចេញវិក្កយបត្រដូចខាងក្រោម៖

---

7 សេចក្តីណែនាំលេខ ៣០៣៣ របស់អគ្គនាយកដ្ឋានពន្ធដារ ឆ្នាំ ២០២០

8 មាត្រា ១០៤ នៃច្បាប់ស្តីពី សារពើពន្ធ ឆ្នាំ ១៩៩៧

- វិក្កយបត្រអាករដល់អតិថិជនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- វិក្កយបត្រធម្មតាដល់អតិថិជនដែលជាអ្នកប្រើប្រាស់

វិក្កយបត្រអាករ ត្រូវមាននិទ្ទេសដូចជា៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ ឬអ្នកផ្គត់ផ្គង់ ។
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះនិងអាសយដ្ឋានអ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្មសារពើពន្ធ
- សេចក្តីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃសរុបនៃប្រភេទទំនិញនីមួយៗដែលមិនទាន់គិតអាករនានា
- ប្រាក់អាករនីមួយៗ (ករណីទំនិញឬសេវាត្រូវជាប់អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ)និងអាករលើតម្លៃបន្ថែម
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់និងអ្នកទិញ។

វិក្កយបត្រធម្មតា ត្រូវមាននិទ្ទេសដូចជា៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកទិញ
- សេចក្តីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃរួមបញ្ចូលទាំងអាករនានានៃទំនិញនីមួយៗ
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់។

## ៣.ការដាក់លិខិតប្រកាស និងបង់ពន្ធ-អាករនានា

### ➢ ពន្ធប្រចាំខែសំខាន់ៗរួមមាន៖

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖ ប្រាក់រំដោះពន្ធនេះត្រូវបង់ជារៀងរាល់ខែតាមអត្រា ១%នៃផលរបររួមទាំងអាករនានាលើកលែងអាករលើតម្លៃបន្ថែម។
- អាករលើតម្លៃបន្ថែម៖ ត្រូវយកអាករលើធាតុចេញតាមអត្រា ១០% កាត់កងអាករលើធាតុចូលដែលអនុញ្ញាត។

- ពន្ធកាត់ទុកលើការជួលៈ អ្នកជាប់ពន្ធមានកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក ដោយត្រូវកាត់ទុកតាមអត្រាដូចមានចែងក្នុងមាត្រា២៥ និងមាត្រា២៦ នៃច្បាប់សារពើពន្ធ។
- ពន្ធលើប្រាក់បៀវត្ស ៖ សម្រាប់សហគ្រាសដែលមានបុគ្គលិកត្រូវជាប់ពន្ធ។

ពន្ធប្រចាំខែត្រូវបង់ពន្ធ និងដាក់លិខិតប្រកាសពន្ធចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី២០ នៃខែបន្ទាប់ នៅអគ្គនាយកដ្ឋានពន្ធដារ ឬដាក់លិខិតប្រកាសតាមប្រព័ន្ធ E-Filing។

➢ **ពន្ធប្រចាំឆ្នាំសំខាន់ៗរួមមានៈ**

- ពន្ធប៉ាតង់ៈ ១ ២០០ ០០០រៀល ក្នុង១ឆ្នាំ សម្រាប់១សកម្មភាព
- ពន្ធលើប្រាក់ចំណូលៈការគណនាប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំណាមួយ ត្រូវយកប្រាក់ចំណូលសរុបប្រចាំឆ្នាំនោះ ដកចំណាយអាចកាត់កងបានតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល គុណអត្រាពន្ធដូចមានចែងក្នុងមាត្រា២០នៃច្បាប់ស្តីពីសារពើពន្ធ។
- ពន្ធអប្បបរមាៈ កំណត់តាមអត្រា ១% លើផលរបរប្រចាំឆ្នាំរួមទាំងអាករនានាលើកលែងអាករលើតម្លៃបន្ថែម (ក្នុងករណីកាន់បញ្ជីគណនេយ្យមិនបានត្រឹមត្រូវ)

ការជាប់ពន្ធប្រចាំឆ្នាំសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រកបអាជីវកម្មដោយឡែក ក្រៅពីប្រភេទពន្ធខាងលើ អាចជាប់ពន្ធអាករដទៃទៀតតាមស្ថានភាពអាជីវកម្ម។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រកបអាជីវកម្មដោយឡែកត្រូវ ចុះបញ្ជីតាមសេចក្តីណែនាំលេខ ៣០៣៣ អពដ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០២០ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

## ការលើកទឹកចិត្តនិងអនុគ្រោះ ផ្នែកពន្ធដារ

សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅ ក្រសួងមហាផ្ទៃ ឬចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវស្ថិតនៅក្រោមនីតិរូប នៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់និងបទបញ្ញត្តិជាធរមាន។

ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ ក្នុងមាត្រា ៩ ចំនុចទី១ (ខ) នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ចំពោះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានរៀបចំឡើងនិងដំណើរការ

សម្រាប់គោលដៅ សុទ្ធសាធខាង សាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ ហើយគ្មានចម្ណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលប្រើប្រាស់ជាឯកជន ដែលមានចែងក្នុងលក្ខន្តិកៈរបស់ខ្លួន ។[9]

គ្រប់ការលើកលែងនិងអនុគ្រោះផ្នែកពន្ធដារទាំងអស់ត្រូវតែមានការស្នើសុំ ទៅរដ្ឋបាលសារពើពន្ធ។

## ទណ្ឌកម្មរដ្ឋបាល និងទោសបញ្ញត្តិ

ចំពោះការប្រព្រឹត្តិអំពើរាំងស្ទះការអនុវត្តបទបញ្ញាត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ចំនួន ២ ០០០ ០០០ (ពីរលានរៀល) ចំពោះបុគ្គលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ។

ការធ្វេសប្រហែសៈ ដែលមានចែងក្នុង មាត្រា១២៥ នៃច្បាប់ស្តីពីសារពើពន្ធបានកំណត់៖

- ប្រាក់ពន្ធបង់ខ្វះ≤ ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ
- មិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬ មិនបានបង់ពន្ធតាមកាលបរិច្ឆេទ ដែលច្បាប់បានកំណត់។ ត្រូវរងពិន័យនិងដាក់ទោសដូចខាងក្រោម ៖
    - ពន្ធបន្ថែម ១០% នៃប្រាក់ពន្ធបង់យឺតឬខ្វះ។
    - ការប្រាក់២% ក្នុងមួយខែ

ការធ្វេសប្រហែសធ្ងន់ធ្ងរៈ ដែលមានចែងក្នុង មាត្រា១២៦ នៃច្បាប់ស្តីពីសារពើពន្ធបានកំណត់៖៖

- ប្រាក់ពន្ធបង់ខ្វះ > ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ ត្រូវរងពិន័យនិងដាក់ទោសដូចខាងក្រោម ៖
    - ពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធបង់ខ្វះ។
    - ការប្រាក់២% ក្នុងមួយខែ
- ការគេចវេសពន្ធៈ បទល្មើសដោយចេតនា ដោយដឹងជាមុន មានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញាត្តិស្តីពីពន្ធដា ក្នុងបំណង បន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញាត្តិស្តីពីពន្ធដាតម្រូវអោយបង់។ ល្មើសមាត្រា ១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ២ លើកដាច់ពីគ្នារយៈពេល ០៣ ឆ្នាំ នៃឆ្នាំប្រតិទិន និងល្មើសមាត្រា ១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ៣ លើកឬច្រើនជាងនេះដាច់ពីគ្នារយៈពេលណាមួយក៏ដោយ។ត្រូវរងពិន័យនិងដាក់ទោសដូចខាងក្រោម ៖
    - ១.ការកំណត់ពន្ធឡើងវិញ

      .ពន្ធបន្ថែម២៥%នៃប្រាក់ពន្ធត្រូវបង់។

      .ការប្រាក់២% ក្នុងមួយខែ
    - ២.ការកំណត់ពន្ធឯកតោភាគី

[9] មាត្រា ៩ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧

.ពន្ធបន្ថែម ៤០%នៃប្រាក់ពន្ធខ្វះ

.ការប្រាក់២% ក្នុងមួយខែ

អភិបាល បណ្ណាធិការ កម្មសិទ្ធិករ ឬបុគ្គលទទួលខុសត្រូវ បានប្រព្រឹត្តអំពើគេចវេសពន្ធ ត្រូវពិន័យពី ១០ ដល់ ២០ លានរៀល ឬជាប់ពន្ធនាគារពី ០១ ដល់ ០៥ ឆ្នាំ ឬ ទោសទាំងពីរនេះ ។

ការប្តឹងចោទប្រកាន់និងទាមទារការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌ លើបទបញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[10]

## សេចក្តីបញ្ជាក់

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

[10] មាត្រា ១៣៤ នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧